# ការទាមទារការទទួលខុសត្រូវពីរដ្ឋ ៖ បទពិសោធន៍របស់សង្គមស៊ីវិល និងប្រជាពលរដ្ឋស្តីពីសិទ្ធិទទួលព័ត៌មាន នៅក្នុងប្រទេសឥណ្ឌា

ទឹកប្រាក់រាប់លានដុល្លារត្រូវបានគេចំណាយមិនចំគោលដៅនៅក្នុងគម្រោងការសុខមាលភាពនៅក្នុងប្រទេសកំពុង អភិវឌ្ឍ និង ប្រទេសមិនទាន់អភិវឌ្ឍ ដោយសារតែស្ថាប័នអភិបាលកិច្ចមានភាពទន់ខ្សោយ ឧទាហរណ៍ មិនមាន ការទទួលខុសត្រូវ ឬ មិននៅក្នុងកន្លែងធ្វើការអនុវត្តន៍។ ជាលទ្ធផល ស្ថានភាពសេដ្ឋកិច្ចសង្គមដ៏ក្រីក្ររបស់ប្រជា ពលរដ្ឋហាក់ដូចជាមិនដែលបានបញ្ចប់ឡើយ នៅក្នុងតំបន់សំខាន់របស់ពិភពលោក។ កត្តានេះហើយដែលធ្វើឱ្យ ការត្រួតពិនិត្យទំនាក់ទំនងរវាងអភិបាលកិច្ច និងស្ថានភាពសេដ្ឋកិច្ចសង្គមមានសារៈសំខាន់។ ការសិក្សាមួយចំនួន ទៅលើការពិនិត្យទំនាក់ទំនងនេះបានបង្ហាញឱ្យដឹងយ៉ាងច្បាស់ថា អភិបាលកិច្ចល្អមានទំនាក់ទំនងជាមួយនឹង GNP ក្នុងកម្រិតមួយខ្ពស់សម្រាប់មនុស្សម្នាក់ៗ អត្រាអក្ខរកម្មរបស់មនុស្សពេញវ័យកើនឡើងខ្ពស់ អត្រាស្លាប់របស់ កុមារមានកម្រិតកាន់តែទាប ហើយអភិបាលកិច្ចមិនល្អ គឺពាក់ព័ន្ធយ៉ាងខ្លាំងជាមួយនឹងការខ្វះគណនេយ្យភាព តម្លាភាព ភាពក្រីក្រ បទឧក្រិដ្ឋ និងអំពើពុករលួយ។ ប្រទេសស្ទើរតែ ៣/៤ ស្ថិតនៅក្នុងក្រុមដែលប្រព្រឹត្តិ អំពើពុករលួយក្នុងការទារពន្ធដារមានពន្ទុក្រោម ៥ (រួមទាំងប្រទេសដែលមានប្រាក់ចំណូលទាបទាំងអស់ ប៉ុន្តែ ដករដ្ឋនៅទ្វីបអាហ្វ្រិកចំនួន ២ ចេញ) ដែលបង្ហាញថា មានទំនាក់ទំនងគ្នាយ៉ាងសំខាន់រវាងអំពើពុករលួយ និង ភាពក្រីក្រ។ [i] វាជាការពិតណាស់ដែលថា អំពើពុករលួយបានឱ្យប្រជាជនក្រីក្រមានការឈឺចាប់ ព្រោះវាបាន បង្វែរទិសសេវាសាធារណៈចេញពីអ្នកទាំងឡាយដែលត្រូវការវាបំផុតនោះ ហើយវាបានធ្វើឱ្យអន្តរាយដល់ស្ថាប័ន ប្រជាធិបតេយ្យ តាមរយៈការទារពន្ធដារមិនត្រឹមត្រូវ ព្រោះថាមានតែស្ថាប័នទាំងនេះទេ ដែលប្រមូលបានប្រាក់ ច្រើនសន្ធឹកសន្ធាប់នៅក្នុងសង្គម។ វាពិតណាស់ថា អភិបាលកិច្ចមិនល្អគឺជាឧបសគ្គចំពោះការអភិវឌ្ឍ និងរុញ ប្រទេសឱ្យស្ថិតនៅដាច់ពីគេ ហើយប្រជាពលរដ្ឋរបស់ប្រទេសទាំងនោះខ្វះការយល់ដឹង។

បញ្ហាប្រឈមនោះ គឺការជំរុញឱ្យស្ថាប័នអភិបាលកិច្ចឱ្យចេះទទួលខុសត្រូវ មានការចូលរួម និងមានតម្លាភាព ទាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍ និងមិនទាន់អភិវឌ្ឍ។ ការធ្វើបែបនេះ សេវាសាធារណៈនឹងត្រូវបានផ្តល់ឱ្យ ប្រកបដោយប្រសិទ្ធភាព។ វិធីសាស្រ្តជាច្រើនសម្រាប់កែប្រែស្ថាប័នអភិបាលកិច្ចត្រូវបានសាកល្បង ប៉ុន្តែមាន ការតែទម្រង់តែមួយប៉ុណ្ណោះដែលសម្រេចបាន គឺភាពមិននៅឯកកោរបស់ប្រជាពលរដ្ឋ។ សេរីភាពសារព័ត៌មាន ជាពិសេសសិទ្ធិទទួលព័ត៌មាន គឺជារបៀបវារៈសំខាន់នៅក្នុងការនិយាយពីគណនេយ្យភាពប្រជាធិបតេយ្យសម្រាប់ពេលបច្ចុប្បន្ន។ ប្រទេសប្រហែល ៦០ បានចាត់វិធានការ ដើម្បីអនុវត្តវា ដោយមាន

កាទទួលស្គាល់ស្របតាម ច្បាប់លក្ខន្តិកៈ។ ប្រទេសទាំងនេះមានឈ្មោះនៅក្នុងបញ្ជីប្រទេសដែលមានប្រវត្តិយូរយា ក្នុងការផ្តល់សិទ្ធិឱ្យទទួល បានព័ត៌មាន រួមមាន ប្រទេសស៊ុយអែត ប្រទេសហ្វាំងឡង់ ប្រទេសហូឡង់ ប្រទេសអូស្ត្រាលី ប្រទេសកាណាដា និងសហរដ្ឋអាមេរិក។

ប្រទេសឥណ្ឌា ក៏បានអនុវត្តតាមជំហានរបស់ប្រទេសផ្សេងៗ ហើយបានអនុម័តច្បាប់សិទ្ធិទទួលបានព័ត៌មាននៅក្នុងឆ្នាំ២០០៥។ ច្បាប់នេះត្រូវបានគេចាត់ទុកថា ជាច្បាប់ដែលមានភាពតឹងរឹង ដោយសារវាបានកំណត់ដាក់ទោសដល់មន្ត្រីរដ្ឋាភិបាលទាំងឡាយណាដែលបានរារាំងមិនឱ្យទទួលបានព័ត៌មាន។ ច្បាប់នេះបានចែងពីយន្តការឆ្ពោះទៅជំរុញឱ្យមានតម្លាភាព និងគណនេយ្យភាពនៅក្នុងអនុវត្តការងាររបស់ស្ថាប័នអភិបាលកិច្ច។ រយៈពេលជិត ៣ ឆ្នាំ បន្ទាប់ពីការធ្វើប្រតិបត្តិការច្បាប់ RTI នៅក្នុងប្រទេសឥណ្ឌា គេអាចវាតម្លៃបានពីវិសាលភាពដែលច្បាប់នេះអាចមានលទ្ធភាពសម្រេចបាននូវគោលដៅរបស់វា។

## ប្រវត្តិនៃសិទ្ធិទទួលបានព័ត៌មាននៅក្នុងប្រទេសឥណ្ឌា

ចលនាទាមទារសិទ្ធិទទួលបានព័ត៌មាន បានចាប់ផ្តើមនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ដោយ Mazdoor Kisaan Shakti Sangathan (ដែលមានឈ្មោះពេញ "អង្គការដើម្បីការផ្តល់អំណាចដល់ពលករ និងកសិករ) នៅក្នុងភូមិ ដាច់ស្រយ៉ាលមួយឈ្មោះ Devdungri (ក្នុងស្រុក Rajsamand, Rajasthan)។ វាគឺជាចលនាមួយដើម្បី លាតត្រដាងពីអំពើពុករលួយនៅក្នុងការងារជួយសង្គ្រោះភាពអត់ឃ្លាន តាមរយៈការស្វែងរកព័ត៌មានពាក់ព័ន្ធនឹង ការចម្លងវិក្កយបត្រ សក្ខីយបត្រ និងបញ្ជីឈ្មោះរួមសម្រាប់ពលករ ដែលត្រូវបានកត់ត្រាទុកនៅក្នុងឯកសាររបស់ រដ្ឋាភិបាល។ ក្រោយពីការព្យាយាមមួយរយៈមក MKSS បានទទួលជោគជ័យ ដោយទទួលបាននូវច្បាប់ចម្លងនៃ ឯកសារ ដែលក្នុងនោះការលួចដកយកមូលនិធិដោយខុសច្បាប់ត្រូវបានបង្ហាញយ៉ាងច្បាស់។ បទពិសោធន៍ជោគ ជ័យនៃការលាតត្រដាងនូវអំពើពុករលួយតាមរយៈសិទ្ធិទទួលបានព័ត៌មាន គឺជាបទពិសោធន៍សម្រាប់ធ្វើការ សិក្សាដ៏ល្អសម្រាប់សង្គមស៊ីវិល ដើម្បីឈានទៅធ្វើការអនុម័ត RTI នៅក្នុង Rajasthan។ រដ្ឋាភិបាលនៅ Rajasthan បានដាក់សម្ពាធលើសកម្មភាពនេះ ហើយក៏បានអនុម័តច្បាប់នៅក្នុងឆ្នាំ ២០០០។

ជោគជ័យក្នុងការតស៊ូរបស់ MKSS បាននាំទៅរកការបង្កើតការពិភាក្សាកាន់តែទូលំទូលាយស្តីពីសិទ្ធិទទួលបានព័ត៌មាននៅក្នុងប្រទេសឥណ្ឌា និងច្បាប់ RTI ត្រូវបានអនុម័តនៅរដ្ឋមួយចំនួនរបស់ប្រទេសឥណ្ឌា។ ការទាមទារ ឱ្យបង្កើតច្បាប់ថ្នាក់ជាតិ បានចាប់ផ្តើមឡើងក្រោមការដឹកនាំនៃយុទ្ធនាការថ្នាក់ជាតិស្តីពីសិទ្ធិទទួលបានព័ត៌មាន របស់ប្រជាជន (NCPRI)។ នៅក្នុងឆ្នាំ១៩៩៦ ក្រុមប្រឹក្សាសារព័ត៌មានរបស់ប្រទេសឥណ្ឌា ដែលដឹកនាំដោយ Justice P B Sawant បានបង្ហាញពីពង្រាងច្បាប់ ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដល់រដ្ឋាភិបាល

ប្រទេសឥណ្ឌា។ ក្រុមការងារមួយ (ហៅថា ណេកម្មាធិការ Shourie) ដែលមានលោក H D Shourie ជាប្រធាន ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលសហព័ន្ធ ហើយបានផ្តល់អណត្តិឱ្យដើម្បីធ្វើការរៀបចំពង្រាងច្បាប់ស្តីពីសេរីភាពទទួលបានព័ត៌មាន។ របាយការណ៍ និងពង្រាងច្បាប់របស់គណៈកម្មាធិការ Shourie ត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៩៧។ តាមពិតទៅ ពង្រាងច្បាប់របស់គណៈកម្មាធិការ Shourie ត្រូវបានគេរៀបចំធ្វើឡើងវិញដើម្បីដាក់បញ្ចូលទៅជាពង្រាងច្បាប់សេរីភាពទទួលបានព័ត៌មាន (FOI) នៅក្នុងឆ្នាំ២០០០ ហើយត្រូវបានអនុម័តនៅក្នុងរដ្ឋសភាក្នុងឆ្នាំ២០០២ ប៉ុន្តែវាមិនត្រូវបានគេប្រកាសឱ្យដឹងនោះទេ។ ទោះជាយ៉ាងយ៉ាងណាក៏ដោយ សង្គមស៊ីវិលបានលើកឡើងនូវការជំទាស់ជាច្រើនទៅនឹងពង្រាងច្បាប់ FOI ហើយបានសំណូមពរឱ្យក្រុមប្រឹក្សាយោបល់ជាតិធ្វើវិសោធនកម្មឡើងវិញ។ ជាលទ្ធផលនៃការតស៊ូអស់យៈពេលយ៉ាងយូររបស់សង្គមស៊ីវិល ច្បាប់ RTI ត្រូវបានគេអនុម័តនៅក្នុងឆ្នាំ២០០៥ នៅក្នុងប្រទេសឥណ្ឌា។ ប៉ុន្តែ មានចម្ងល់សំខាន់មួយ ថាតើច្បាប់ RTI អាចក្លាយជាយន្តការដ៏មានប្រសិទ្ធិភាពដើម្បីធានាឱ្យមានគណនេយ្យភាពនៅក្នុងស្ថាប័នអភិបាលកិច្ចដែរ ឬ ទេ? វាបានធ្វើឱ្យការវិភាគ អំពីទំនាក់ទំនងរវាងគណនេយ្យភាព និងច្បាប់ RTI សមហេតុផល។

## គណនេយ្យភាព និងច្បាប់ RTI

យោងតាមការសិក្សាភាគច្រើនបំផុត បានបង្ហាញឱ្យដឹងថា របបប្រជាធិបតេយ្យនៅក្នុងប្រទេសឥណ្ឌាបានទទួល រងផលប៉ះពាល់នៃឱនភាពមួយចំនួន ដូចជា កង្វះតម្លាភាព និងគណនេយ្យភាពនៅក្នុងការអនុវត្តការងាររបស់ ស្ថាប័នសាធារណៈ ការអនុវត្តច្បាប់មានភាពទន់ខ្សោយក្នុងការធានាសិទ្ធិរបស់បុគ្គល សិទ្ធិជាក្រុម និងសន្តិសុខ គ្មានស្ថាប័នប្រកបដោយប្រសិទ្ធភាពសម្រាប់ត្រួតពិនិត្យអំពើពុករលួយ គ្មានវិធីសាស្ត្រចូលរួមក្នុងបង្កើតគោល នយោបាយ និងការផ្តល់សេវាដោយស្ថាប័នរដ្ឋាភិបាលមានភាពទន់ខ្សោយ។ ជាលទ្ធផលនៃឱនភាពប្រជាធិបតេយ្យនេះ ប្រទេសឥណ្ឌានៅតែបន្តធ្វើដំណើរវិលវល់ជុំវិញភាពក្រីក្រ និងការអភិវឌ្ឍមានកម្រិតទាប។ ការរីករាលដាល នៃអំពើពុករលួយដែលកើតចេញមកពីកង្វះយន្តការគណនេយ្យភាពប្រកបដោយប្រសិទ្ធភាពនៅក្នុងវិស័យផ្សេងៗគ្នានៃរដ្ឋបាលសាធារណៈ ប្រជាពលរដ្ឋទូទៅនៅតែដើរតួយ៉ាងសំខាន់នៅក្នុងការអនុវត្តរបបប្រជាធិបតេយ្យ ព្រោះភាពខ្វះខាតនេះធ្វើឱ្យធ្លាក់ចុះ និងបង្កអន្តរាយដល់ស្ថាប័នប្រជាធិបតេយ្យនៅក្នុងប្រទេសឥណ្ឌា។

ការប៉ុនប៉ងមួយចំនួនត្រូវបានធ្វើឡើងដើម្បីបង្ហាញពី *"ឱនភាពលទ្ធិប្រជាធិបតេយ្យ"* តាមរយៈការពង្រឹងយន្តការ គណនេយ្យភាពផ្ទៃក្នុង ដែលរួមមាន ធ្វើការបង្កើតស្ថាប័នរដ្ឋបាល ដូចជា នាយកដ្ឋានសវនកម្ម, *Lok Ayukya* (អ្នកត្រួតពិនិត្យបណ្តឹងឯករាជ្យ), ការិយាល័យស៊ើបអង្កេតថ្នាក់កណ្តាល, អ្នកត្រួតពិនិត្យគណនី

និងអគ្គសវនករ របស់ប្រទេសឥណ្ឌា និងគណៈកម្មការកណ្តាលសម្រាប់តាមដាន ប៉ុន្តែវិធានការទាំងនេះបានត្រឹមតែល្អមើលប៉ុណ្ណោះ ព្រោះថា ស្ថាប័នទាំងនេះ មិនត្រូវបានផ្តល់ស្វ័យភាព និងអំណាចដែលចំបាច់ដើម្បីដំណើរការប្រកបដោយប្រសិទ្ធភាព។ ជាលទ្ធផល យន្តការគណនេយ្យភាពផ្ទៃក្នុងទទួលបរាជ័យក្នុងការចែកចាយ នៅខណៈពេលដែល យន្តការគណនេយ្យភាពផ្នែកខាងក្រៅត្រូវបានចាត់ទុកថា ជាយន្តការគណនេយ្យភាពសង្គមផងដែរនោះ ដូចជា *Jun Sunwais (សាវការសាធារណៈ) និងការត្រួតពិនិត្យប្រជាពលរដ្ឋ/របាយការណ៍, យុទ្ធនាការ (សារព័ត៌មាន និងប្រព័ន្ធឃោសនាមហាជន)* លើកលែងតែក្នុងករណីមួយចំនួន មិនត្រូវបានគេប្រើប្រាស់ទូលំទូលាយនៅក្នុង ប្រទេសឥណ្ឌា។

## សិទ្ធិទទួលព័ត៌មាន : កត្តាសំខាន់១

ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដែលចូលជាធរមាននៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ គឺជាច្បាប់មួយក្នុងចំណោម ច្បាប់សំខាន់ៗភាគច្រើនដែលបានអនុម័តដោយរដ្ឋសភារបស់ប្រទេសឥណ្ឌា។ ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានក្នុងឆ្នាំ ២០០៥ (ច្បាប់ RTI ) ទទួលស្គាល់ថា នៅក្នុងលទ្ធិប្រជាធិបតេយ្យ ដូចជាប្រទេសឥណ្ឌានេះ ព័ត៌មានទាំងអស់ ដែលគ្រប់គ្រងដោយរដ្ឋាភិបាល ត្រូវតែបើកចំហទៅដល់ប្រជាជនគ្រប់រូបនៅទីបញ្ចប់។ ការបើកចំហព័ត៌មានដល់ ប្រជាពលរដ្ឋ គឺជាផ្នែកមួយនៃការបំពេញតួនាទីជាធម្មតារបស់រដ្ឋាភិបាល ព្រោះថា សាធារណៈជនមានសិទ្ធិដឹង នូវអ្វីដែលមន្ត្រីរដ្ឋធ្វើជាមួយនឹងប្រាក់របស់ពួកគេ។ ច្បាប់នោះចែងថា តម្លាភាព គឺជាបរិបទមួយ ហើយការលាក់ ការសម្ងាត់ គឺជាករណីលើកលែងមួយនៅក្នុងដំណើរការអនុវត្តការងាររបស់ស្ថាប័នរដ្ឋាភិបាល។

## មធ្យោបាយងាយស្រួលសម្រាប់ការទទួលបានព័ត៌មាន

ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ផ្តល់សិទ្ធិឱ្យប្រជាពរដ្ឋឥណ្ឌាទាំងអស់ ដើម្បីទទួលបានព័ត៌មានពីស្ថាប័នសាធារណៈ។ នីតិវិធីក្នុងការស្នើសុំព័ត៌មាន គឺមានភាពសាមញ្ញ ហើយប្រជាពលរដ្ឋអាចទទួលបាន។ ពាក្យស្នើសុំមានសរសេរ ជាភាសារអង់គ្លេស និងហិណ្ឌូ (Hindi) ឬ ភាសាផ្លូវការណ៍របស់រដ្ឋ។ ចំពោះពាក្យស្នើសុំនេះត្រូវដាក់ភ្ជាប់ មកជាមួយនូវតម្លៃបំពេញបែបបទដែលចាំបាច់ ដូចមានចែងនៅក្នុងច្បាប់របស់រដ្ឋ។ បែបបទស្នើសុំនេះត្រូវដាក់ ទៅមន្ត្រីព័ត៌មានសាធារណៈ (PIO) នៅក្នុងស្ថាប័នរដ្ឋ ជាកន្លែងដែលគេចង់បានព័ត៌មាននោះ។ វគ្គទី ៤ នៃច្បាប់ RTI បានកំណត់អាណត្តិសម្រាប់ស្ថាប័នរដ្ឋនីមួយៗ ឱ្យបង្ហាញដោយស្ម័គ្រចិត្តពីសកម្មទាំងអស់របស់ពួកគេ នៅក្នុងសៀវភៅមួយ ដើម្បីឱ្យប្រជាពលរដ្ឋអាចទទួលបានព័ត៌មានស្តីពីមុខងារសំខាន់ៗរបស់ស្ថាប័នរដ្ឋ ដោយមិនចាំបាច់ដាក់ពាក្យស្នើសុំ។

## តួនាទី និងទំនួលខុសត្រូវរបស់មន្ត្រីព័ត៌មានរដ្ឋ

មន្ត្រីព័ត៌មានរដ្ឋ (PIOs) គឺជាមន្ត្រីដែលបានតែងតាំងនៅក្នុងអង្គភាព និងការិយាល័យរដ្ឋបាលទាំងអស់របស់ស្ថាប័នរដ្ឋ ហើយត្រូវបានគេដាក់បន្ទុកឱ្យទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានដល់អ្នកដែលបានស្នើសុំព័ត៌មានស្របតាមច្បាប់។ PIO ត្រូវតែផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋក្នុងរយៈ ៣០ថ្ងៃ បន្ទាប់ពីទទួលបានពាក្យស្នើសុំ។

## ដំណើរការបណ្តឹងឧទ្ធរណ៍

ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន បានចែងពីការរៀបចំបែបបទដាក់បណ្តឹងឧទ្ធរណ៍លើកទី១ និងលើកទី ២ សម្រាប់ ករណីមានការបដិសេធមិនព្រមផ្តល់ព័ត៌មាន។ ជំពូកទី ១៩ នៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានបានចែងពីការប្តឹង ឧទ្ធរណ៍ជាពីរដំណាក់កាលប្រឆាំងនឹងការសម្រេចរបស់ PIOs ចំពោះអ្នកដាក់ពាក្យសុំ។ អ្នកដាក់ពាក្យដែលមិន បានទទួលព័ត៌មានក្នុងរយៈពេល ៣០ថ្ងៃ ឬ មិនពេញចិត្តចំពោះការសម្រេចរបស់ PIOs អាចដាក់ពាក្យបណ្តឹង ឧទ្ធរណ៍ទៅអាជ្ញាធរសាលាឧទ្ធរណ៍ទីមួយ ដែលជាទូទៅ ជាមន្ត្រីជាន់ខ្ពស់ទទួលបានការតែងតាំងនៅក្នុងនាយក ដ្ឋានរដ្ឋាភិបាល (ជាស្ថាប័នរដ្ឋដែលគេបានដាក់ពាក្យសុំ)។ ប្រសិនបើអ្នកដាក់ពាក្យសុំមិនពេញចិត្តនឹងការសម្រេច របស់អាជ្ញាធរសាលាឧទ្ធរណ៍ទីមួយ គេអាចដាក់បណ្តឹងឧទ្ធរណ៍លើកទី ២ ទៅគណៈកម្មការព័ត៌មានថ្នាក់កណ្តាល (CIC) ឬ ទៅគណៈកម្មការព័ត៌មានរដ្ឋ (SIC) ទៅតាមករណីដែលអាចធ្វើទៅបាន។

## អំណាច និងតួនាទីរបស់គណៈកម្មការព័ត៌មាន

គណៈកម្មការព័ត៌មានថ្នាក់កណ្តាល/រដ្ឋ គឺជាអាជ្ញាធរសាលាឧទ្ធរណ៍កំពូលនៅថ្នាក់កណ្តាល/រដ្ឋ សម្រាប់បើកសាវ នការបណ្តឹងឧទ្ធរណ៍ ឬ ពាក្យបណ្តឹងពីប្រជាពលរដ្ឋដែលមិនអាចទទួលបានព័ត៌មានដោយសារមូលហេតុផ្សេងៗ។ អំណាចក្នុងការដាក់ឱ្យអនុវត្ត និងស្របតាមច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបានផ្តល់ឱ្យគណៈកម្មការព័ត៌មាន ថ្នាក់កណ្តាល ឬ គណៈកម្មការព័ត៌មានថ្នាក់រដ្ឋ។ គណៈកម្មការព័ត៌មានថ្នាក់កណ្តាល/ថ្នាក់រដ្ឋ អាចកោះហៅ និងនាំ ខ្លួនមនុស្ស ឬ ឯកសារទាំងឡាយ ធ្វើការស្រាយជ្រាវ និងត្រួតពិនិត្យឯកសារ។ល។ នៅពេលបើកសាវនការ បណ្តឹងឧទ្ធរណ៍ ប្រសិនបើ CIC/SIC រកឃើញថា PIO បានបដិសេធមិនផ្តល់ព័ត៌មានដោយចេតនា ឬ ផ្តល់ព័ត៌ មានមិនត្រូវ នៅពេលនោះ សាលានេះអាចធ្វើការផាកពិន័យកម្រិតអតិបរមាដល់ទៅ ២៥ 000 រូពី ហើយអាច នឹងចាត់វិធានការដាក់ពិន័យផ្លូវច្បាប់ប្រឆាំងនឹង PIO នោះទៀតផង។

## តួនាទីរបស់រដ្ឋាភិបាលថ្នាក់កណ្តាល/ថ្នាក់រដ្ឋ

រដ្ឋបាលថ្នាក់កណ្តាល/ថ្នាក់រដ្ឋ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអនុវត្តច្បាប់។ ជំពូកទី ២៦ នៃច្បាប់នេះបានចែង ថា ត្រូវតែចាត់វិធានការធ្វើការអភិវឌ្ឍ និងរៀបចំកម្មវិធីអប់រំ ដែលឈានទៅពង្រីកការយល់ដឹងរបស់

សាធារណ ជនស្តីពីច្បាប់ RTI ជាពិសេស សហគមន៍ក្រីក្រ ដើម្បីបណ្តុះបណ្តាល PIOs និងចងក្រងឯកសារពាក់ព័ន្ធនឹងការ បណ្តុះបណ្តាលដើម្បីទុកឱ្យប្រើប្រាស់នៅតាមស្ថាប័នរដ្ឋ។ គេមានសិទ្ធិបង្កើតច្បាប់ពាក់ព័ន្ធនឹងថ្លៃ និងការចំណាយ ដើម្បីទទួលបានព័ត៌មាន។ ក្រសួង និងនាយក ដ្ឋានក្នុងរដ្ឋាភិបាលមានទំនួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ ប្រចាំឆ្នាំ និងថែរក្សាកំណត់ត្រាសម្រាប់គោលបំណងទាំងនោះ។ ដូច្នេះហើយ រដ្ឋាភិបាលថ្នាក់កណ្តាល/រដ្ឋ ត្រូវបាន ដាក់បន្ទុកឱ្យអនុវត្តខ្លឹមសារនៃច្បាប់ RTI ក្នុងចំណោមមហាជនតាមមធ្យោបាយផ្សេងៗ។

## បទពិសោធន៏របស់ប្រជាពលរដ្ឋពីឆ្នាំ២០០៧-២០០៨

ក្នុងការសិក្សានៅឆ្នាំ២០០៧ ៧៥%នៃអ្នកឆ្លើយបត បានបង្ហាញថា បញ្ជីរបស់ PIOs មិនអាចរកបានទេនៅថ្នាក់ ស្រុក ហើយ ៧២% នៃការិយាល័យរដ្ឋាភិបាលដែលប្រជាពលរដ្ឋព្យាយាមរកព័ត៌មាននោះ មិនបានបង្ហាញព័ត៌មាន ផ្ទាល់របស់គេទេ។ ការសិក្សានៅឆ្នាំ២០០៨ បង្ហាញថា ប្រជាពលរដ្ឋជិត ៩០% មិនបានទទួលបញ្ជីព័ត៌មានរបស់ PIOs ទេ ហើយពួកគេមិនឃើញមានការបង្ហាញព័ត៌មានរបស់គេនោះទេ នៅក្នុងការិយាល័យរដ្ឋាភិបាល។ ពួកគេក៏បានបង្ហាញផងដែរថា របៀបរបបនៃការបង់ប្រាក់ត្រូវបានគេកំណត់នៅ Bihar, Kerala, Madhya Pradesh, Gujarat, Orissa ហើយភាពស្មុគស្មាញនៃនីតិវិធីបានកំពុងតែរារាំងការដាក់ពាក្យសុំ Karnataka, Madhya Pradesh, Orissa និង Punjab ។

យោងតាមភាគរយគួរឱ្យកត់សម្គាល់របស់អ្នកឆ្លើយតបនៅក្នុងឆ្នាំទាំងពីរនោះ គេបានរកឃើញថា PIOs មិនបាន សហការខ្លាំងក្លានោះទេ ហើយក៏មានការបង្ហាញផងដែរតាមរយៈករណីជាច្រើន ពីការគំរាមកំហែងដល់អ្នកដាក់ ពាក្យសុំនៅ Bihar, Uttar Pradesh, Haryana និង Orissa ។ លោក Ved Prakash ជាប្រធាន *Suparbhat Sewa Samiti*, (អង្គការសង្គមស៊ីវិល), ស្រុក Sonipat ក្នុងរដ្ឋ Haryana បានប្រឈមមុខនឹងលទ្ធផលដ៏ជូចត់ ដោយសារតែគាត់បានដាក់ពាក្យសុំមើលព័ត៌មានចំនួន ៥១ដង។ ផ្ទះរបស់គាត់មួយផ្នែកត្រូវបានកំទេចដោយមន្ត្រី រដ្ឋាភិបាលដែលគាត់បានធ្វើការស៊ើបអង្កេតជាញឹកញាប់ពីការបំពេញតួនាទីរបស់ពួកគេដោយផ្អែកលើច្បាប់ RTI នោះ។ (ប្រភព : របាយការណ៍ PRIA – Haryana) កសិករស្លូតត្រង់ម្នាក់មានអាយុ ៤៨ឆ្នាំ ឈ្មោះ Shiv Prakash Rai ត្រូវបានចាប់ឃុំឃាំងដោយតុលាការី (DM) នៃស្រុក Buxar, Vishnudeo Prasad ពីបទស្វែងរកព័ត៌មានពិតប្រាកដ ស្របតាមច្បាប់ RTI នៅខែឧសភា ឆ្នាំ២០០៨។ គាត់ត្រូវបានគេដោះលែង ខណៈដែលចំណាត់ការរបស់ប៉ូលិសបានរកឃើញថា សំណុំរឿងនោះមិនមែនជាការពិត។ នៅពេលក្រោយមក DM ត្រូវបានផាកពិន័យដោយ SIC ពីបទបដិសេធមិនផ្តល់ព័ត៌មានទៅឱ្យ Prakash Rai ។

ក្រៅពីនោះ អត្រាដ៏ច្រើននៃអ្នកផ្តល់ចម្លើយនៅក្នុងរយៈពេលពីរឆ្នាំនោះ បានបង្ហាញថា អាជ្ញាធរសាលាឧទ្ធរណ៍ទីមួយមានការប្រងើយ កន្តើយក្នុងការផ្តល់ព័ត៌មាន។

ការអនុវត្តការងាររបស់គណៈកម្មការ អាជ្ញាធរសាលាឧទ្ធរណ៍ទី២ មិនមានការពេញចិត្តពីសំណាក់អ្នកផ្តល់ចម្លើយ នោះឡើយក្នុងយេៈពេលពីរឆ្នាំនោះ។ ការពន្យារពេលដើម្បីទាត់ចោលការប្តឹងឧទ្ធរណ៍ គុណភាពនៃការសម្រេច មានកម្រិតទាប អកប្បកិរិយាយោគយល់ចំពោះមន្ត្រីរដ្ឋាភិបាល គឺជាមូលហេតុបង្កឱ្យមានកង្វល់នៅក្នុងចំណោម អ្នកប្រើប្រាស់ច្បាប់ RTI ផងដែរ។ ផ្អែកលើការបង្ហាញរបស់សមាជិកដែលធ្លាប់មានមុខងារនៅផ្នែករដ្ឋបាល និងអភិបាលកិច្ចនៅក្នុងគណៈកម្មការព័ត៌មាន ជាពិសេស មន្ត្រីសេវារដ្ឋបាលចូលនិវត្តន៍របស់ប្រទេសឥណ្ឌា (IAS) បានបន្ថែមទៅលើការយល់ឃើញនោះផងដែរថា គណៈកម្មការព័ត៌មាន គឺជាមន្ត្រីដែលលំអៀងទៅខាងរដ្ឋាភិបាល ហើយប្រឆាំងនឹងប្រជាពលរដ្ឋ ់។ គួរឱ្យកត់សម្គាល់ត្រង់ចំណុចនេះផងដែរថា អត្រានៃការច្រានចោលបណ្តឹង ឧទ្ធរណ៍មានការកើនឡើងនូវក្នុងរដ្ឋមួយក្នុងអំឡុងឆ្នាំ២០០៧ ដល់ឆ្នាំ២០០៨។ ប៉ុន្តែ ចំនួននៃការផាកពិន័យដែល បានធ្វើចំពោះមន្ត្រីរដ្ឋាភិបាលដោយមន្ត្រី SICs នៅក្នុងរដ្ឋមួយចំនួមានការកើនឡើយក្នុងកម្រិតតិចតួចប៉ុណ្ណោះ។ លើកលែងតែ Andhra Pradesh, Uttarakhand និង Haryana SIC, អ្នកផ្តល់ចម្លើយយល់ឃើញថា ដោយមិនសង្កត់ធ្ងន់លើតែមន្ត្រីនោះទេ គណៈកម្មការព័ត៌មានកំពុងតែបង្ហាញឱ្យឃើញពីភាពរអាក់រអួលសំខាន់ៗ ក្នុងការអនុវត្តច្បាប់ RTI។ ទោះបីជាយ៉ាងនេះក្តី SICs នៅក្នុងរដ្ឋមួយចំនួនដូចជា Andhra Pradesh, Haryana, Uttarakhand និង Gujarat កំពុងព្យាយាមរឹតបន្តឹងប្រព័ន្ធរបស់ខ្លួនតាមរយៈការកែលម្អនូវ អត្រាច្រានចោល និងការដាក់ទោសទណ្ឌ។ ជាការពិត គំនិតផ្តួចផ្តើមរបស់ Andhra Pradesh និង Punjab SIC និងគណៈកម្មការព័ត៌មានថ្នាក់កណ្តាលពាក់ព័ន្ធនឹងការបង្ហាញឱ្យឃើញពីខ្លួនឯងត្រូវបានគេចាត់ទុកថា មានភាពល្អ ប្រសើរ។ នៅខណៈដែលមានការបង្ហាញពីការផ្តល់ប្រាក់ខែតិចតួចដល់ SICs និងមិនមានការជំរុញឱ្យមានការ យល់ដឹងក្នុងចំណោមអ្នកជំនាន់ក្រោយ វិធានការរបស់រដ្ឋបាលថ្នាក់រដ្ឋនេះត្រូវបានគេមើលឃើញថា មានភាព ព្រងើយកន្តើយយ៉ាងខ្លាំង។

ថ្វីបើប្រជាពលរដ្ឋបានប្រឈមមុខនឹងការលំបាករាប់មិនអស់ក៏ដោយ ក៏ពួកគេនៅបន្តប្រើប្រាស់ច្បាប់ RTI នេះ ទៀត។ ការសិក្សានៅឆ្នាំ២០០៨ បង្ហាញថា អ្នកផ្តល់ចម្លើយ ៦៨% មានការពេញចិត្តនឹងព័ត៌មានដែលបានផ្តល់ ឱ្យ។ ទោះបីជាមិនមានការវាយតម្លៃពីប្រសិទ្ធភាពនៃច្បាប់ RTI ពាក់ព័ន្ធនឹងទិដ្ឋភាពសុខមាលភាព ឬនាយកដ្ឋាន រដ្ឋាភិបាលក៏ពិតមែន ប៉ុន្តែការសិក្សាពីករណីជាច្រើននៅក្នុងផ្នែកផ្សេងៗគ្នាទូទាំងប្រទេសបានបង្ហាញថាការផ្តល់ សេវាកម្ម និងសិទ្ធិផ្សេងៗដល់អ្នកប្រើប្រាស់ច្បាប់ RTI មានភាពប្រសើរឡើង។ ការរីកសាយនៃការ

ប្រើប្រាស់ច្បាប់ RTI ពិតជាបានជំរុញស្ថាប័នអភិបាលកិច្ចឱ្យចាត់វិធានការអនុវត្តច្បាប់ ព្រោះពួកគេមានការភ័យខ្លាចចំពោះ ការចោទប្រកាន់ពីមុខងារដ៏ទន់ខ្សោយ និងអំពើពុករលួយ ។

**ប្រសិទ្ធភាព**

ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបានប្រើប្រាស់ដោយប្រជាជនក្រីក្រ និងប្រជាជនភាគតិចទៅទូទាំងប្រទេស ទោះបីជាមានការរារាំងជាច្រើនបង្កឡើងដោយនាយកដ្ឋានរដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាល និងការខ្វះការយល់ដឹងពីច្បាប់ នេះក៏ដោយ ។ ពួកគេបានប្រើច្បាប់ RTI ដើម្បីដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងសេវាទាំងឡាយ ដូចជា ទឹក អគ្គិសនី ផ្លូវថ្នល់ ។ល។ ហើយទទួលបានសិទ្ធិប្រើប្រាស់ ដូចជា កាតស្ថិតក្រោមបន្ទាត់ភាពក្រីក្រ (BPL), ប្រាក់សោធននិវត្តន៍ អាហារូបករណ៍ កាតទទួលបានការងារស្ថិតក្រោមគម្រោងធានាការអភិវឌ្ឍតំបន់ជនបទថ្នាក់ ជាតិ លំនៅដ្ឋានស្ថិតក្នុងគម្រោងផ្តល់ទីជម្រកប្រទេសឥណ្ឌា (*Awas Yojana*) និងប័ណ្ណអ្នកបោះឆ្នោតពី ការិយាល័យបោះឆ្នោត ។ល។ នៅតាមទីតាំងជាច្រើន ប្រជាពលរដ្ឋបានរៀបចំសាវនការសាធារណៈ ហើយរៀបចំ ប័ណ្ណរបាយការណ៍របស់ប្រជាជន ដើម្បីទទួលបានកម្មវិធីសុខមាលភាព ការត្រួតពិនិត្យសំណង់ផ្លូវថ្នល់ ស្រះទឹក លូបង្ហូរទឹក សាលារៀន និងសំណង់សាធារណៈផ្សេងៗទៀត ។ [សូមមើលប្រអប់ ១] ទិន្នន័យសម្រាប់សាវនការ និងកាតរបាយការណ៍ ។ល។ គម្រោងថវិកា បញ្ជីឈ្មោះរួម ផលប្រយោជន៍នានាអាចទទួលបានតាមរយៈច្បាប់ RTI ហើយដែលពួកគេមិនអាចទទួលបានវាបានពីស្ថាប័នរដ្ឋាភិបាល ។ សូម្បីតែអ្នកសារព័ត៌មានក៏មានលទ្ធភាព ទទួលបានព័ត៌មានពិតស្របច្បាប់ផងដែរ ពាក់ព័ន្ធនឹងការអនុវត្តមិនត្រឹមត្រូវការអនុវត្តការងារមានភាពទន់ ខ្សោយ អំពើពុករលួយ ។ល។ នៅក្នុងស្ថាប័នគ្រប់គ្រង ។ ដូច្នេះហើយ ច្បាប់ RTI បានបង្កើតឱ្យមានភាពភ័យខ្លាច នៅក្នុងចិត្តរបស់មន្ត្រីរដ្ឋាភិបាលថា ការជាប់ពាក់ព័ន្ធរបស់ពួកគេក្នុងការអនុវត្តមិនត្រឹមត្រូវអាចនឹងត្រូវបានគេ បរិហារ ដែលនេះជាហេតុបង្កឱ្យមន្ត្រីទាំងនោះមានការស្ទាក់ស្ទើរក្នុងការរំលោភច្បាប់ ។

**ប្រអប់លេខ ១**

**១. ការសិក្សារបស់ PRIA ធ្វើឱ្យមានការប្រែប្រួលនៅក្នុងរដ្ឋសភាប្រទេសឥណ្ឌា**

ការសិក្សាមួយដែលធ្វើឡើងដោយ PRIA នៅក្នុងឆ្នាំ២០០៧ ត្រូវបានបោះពុម្ពផ្សាយនៅក្នុងកាសែតជាតិ សំខាន់ៗភាគច្រើននៅក្នុងប្រទេស ។ ជាលទ្ធផលនៃការរីកសាយនៃការបោះពុម្ពផ្សាយនេះ សមាជិករដ្ឋសភា ប្រទេសឥណ្ឌាបានដឹងអំពីការរារាំង ដែលប្រឈមដោយប្រជាពលរដ្ឋក្នុងការទទួលបាន

ព័ត៌មាន ស្របតាម ច្បាប់ RTI នៅក្នុងប្រទេស។ សំនួរដែលពាក់ព័ន្ធទៅនឹងការអនុវត្តការងាររបស់ស្ថាប័នរដ្ឋស្តីពីកាអនុវត្តច្បាប់ RTI ត្រូវបានលើកឡើងនៅក្នុងរដ្ឋសភាប្រទេសឥណ្ឌា។ ការសិក្សាក៏បានចូលរួមជាមួយរដ្ឋបាលរបស់រដ្ឋផង ដែរ។ ការរួបរួមគ្នានោះបានចាប់ផ្តើមដោទទួលបានលទ្ធផលចំនួន - Haryana SIC បានចាត់វិធានការតឹងរ៉ឹង ដើម្បីអនុវត្តច្បាប់ RTI រហូតដល់ធ្វើការដាក់ទោសទណ្ឌមន្ត្រីរដ្ឋាភិបាលពីបទបដិសេធមិនផ្តល់ព័ត៌មានទៀត។ រដ្ឋាភិបាលរបស់លោក Himachal Pradesh បានចូលរួមជាមួយសង្គមស៊ីវិលក្នុងការរៀបចំសៀវភៅ ណែនាំច្បាប់ RTI សម្រាប់មន្ត្រី និងប្រជាពលរដ្ឋ។ ការតែងតាំងសមាជិកឱ្យធ្វើការជាមួយសង្គមស៊ីវិល ច្បាប់ និងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា បានចាប់ផ្តើមកើតមានឡើងនៅក្នុងរដ្ឋ/គណ:កម្មការព័ត៌មានថ្នាក់កណ្តាល។

ប្រភព : របាយការណ៍ប្រចាំឆ្នាំរបស់ PRIA ២០០៧-០៨

---

**២. ការបង្កើនប្រព័ន្ធចែកចាយសារធាណ:នៅក្នុង Uttar Pradesh**

ស្ថិតក្រោមប្រព័ន្ធចែកចាយសាធាណ: អ្នកភូមិ Almapur បានទទួលរបបអាហាររបស់ពួកគេជារៀងរាល់ឆ្នាំ ប៉ុន្តែវាមានតែនៅក្នុងក្រដាសប៉ុណ្ណោះ។ គេមិនបានទទួលរហូតដល់ឆ្នាំ២០០៦ — ក្រោយពីមានការស្នើសុំ ធ្វើការពិនិត្យព័ត៌មានជាក់ស្តែងស្របតាមច្បាប់ RTI ទើបពួកគេបានទទួលវា។

Sandeep Pandey ជាអ្នកតំណាងសហគមន៍នៃសម្ព័ន្ធភាពជាតិចលនាប្រជាជន បានមានប្រសាសន៍ថា “របបអាហារត្រូវបានគេផ្តល់ឱ្យពិតមែន ប៉ុន្តែវាត្រូវមន្ត្រីខិលខូចមួយចំនួនយកទៅលក់នៅតាមទីផ្សារ។ យើងបានប្រមូលផ្តុំប្រជាជន ហើយប្រាប់ពួកគេឱ្យថា របបអាហារក្នុងកម្រិតសមស្របត្រូវបានគេផ្តល់ឱ្យពួក យើង”។ ជាលទ្ធផល កាលពី ២ឆ្នាំមុន អ្នកភូមិបានដាក់ពាក្យបណ្តឹងតវ៉ាស្តីពីច្បាប់ RTI។

Ram Babu ជាប្រជាពលរដ្ឋនៅក្នុងភូមិ Natpurwa នៅ Hardoi បាននិយាយថា “បន្ទាប់ពីបានទទួលព័ត៌មាន ពួកយើងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយនៅពេលនោះ យើងបានសម្រេចចិត្តធ្វើបាតុកម្មដើម្បីលើកឡើង នូវការបំពានដែលគេបានធ្វើ។ ទីបញ្ចប់ ទោសកំហុសនោះត្រូវបានសរសេរចូលទៅក្នុងសៀវភៅ ហើយសព្វថ្ងៃ នេះ ស្ថានភាពនោះមានភាពប្រសើរឡើងយ៉ាងឆាប់រហ័ស”។ គេបាននិយាយថា ត្រឹមតែក្នុងរយ:ពេល ២០ថ្ងៃ ប៉ុណ្ណោះ ពួកអ្នកភូមិក្រីក្រចាប់ផ្តើមទទួលបានរបបអាហារ ដែលនោះជាលើកទីមួយហើយចាប់តាំងពី ទទួល បានឯករាជ្យ - ហើយអាជ្ញាប័ណ្ណរបស់ហាងលក់អាហារប្រហែល

៣០០កន្លែងត្រូវបានគេលុបចោល ” ។

ប្រភព : Hindustan Times, New Delhi, ថ្ងៃសុក្រ ទី១៧ ខែតុលា ឆ្នាំ២០០៨

-------------------------------------------------------------------------------------------------------------------------

### ៣. **ការលាតត្រដាងអំពើពុករលួយ – Maharashtra**

ព័ត៌មានដែលបានបង្ហាញឱ្យដឹងដោយពាណិជ្ជករចូលនិវត្តន៍ម្នាក់ និងដោយមានការតាមដានជាបន្តបន្ទាប់ជា មួយនឹងមន្ត្រីរដ្ឋបាល និងអ្នកតំណាងដែលជាប់ឆ្នោតនៅក្នុងយុទ្ធនាការមួយដែលរៀបចំឡើងដោយក្រុមប្រជា ពលរដ្ឋនោះ បានបង្ខំឱ្យស្ថាប័នតំណាងប្រជាពលរដ្ឋរបស់ Mumbai ប្តេជ្ញាចិត្តធ្វើការពិនិត្យឡើងវិញនូវផែន ការរបស់ខ្លួនក្នុងការអនុញ្ញាតឱ្យស្ថាបនិកឯកជនធ្វើការអភិវឌ្ឍដែនដី Mumbai - ផ្សារ Crawford ។

ពាណិជ្ជករ Shailesh Gandhi ដែលសព្វថ្ងៃនេះជាប្រធានគណៈកម្មការព័ត៌មានថ្នាក់កណ្តាល បានប្រើច្បាប់ RTI ដើម្បីត្រួតពិនិត្យមើលឯកសារ។ នៅពេលនោះ គាត់បានគណនាតួលេខដើម្បីឈានទៅធ្វើការសន្និដ្ឋាន ថា សំណើរបស់ក្រុមហ៊ុនសារជីវកម្មទីក្រុង Brihanmumbai ដែលសុំឱ្យប្រគល់បរិវេណទីផ្សារចំនួន ១ ៨៦៩ និងទីតាំងក្តើតំណែលស្ថិតក្រោមការការពារឱ្យទៅស្ថាបនិក ដើម្បីធ្វើការអភិវឌ្ឍឡើងវិញនោះនឹងធ្វើឱ្យ ស្ថាប័នតំណាងប្រជាពលរដ្ឋខាតបង់ប្រាក់ចំនួន ១០ ០០០លានរូពី។ ជាការដោះដូរក្រុមហ៊ុនសារជីវកម្មនោះ នឹងធ្វើការសាងសង់ដោយមិនគិតថ្លៃក្នុងតម្លៃទឹកប្រាក់ត្រឹមតែ ៤០០លានរូពីប៉ុណ្ណោះ។ បន្ទាប់មក គាត់បាន ដឹកនាំយុទ្ធនាការប្រឆាំងនឹងការផ្លាស់ប្តូរនោះ។ កាលពីខែកញ្ញាមុននៅពេលដែលសំណើបានបញ្ជូនទៅដល់ ការិយាល័យតំណាងប្រជាពលរដ្ឋ សមាជិកក្រុមព្រឹក្សាបានប្រឈមមុខជាមួយក្រុមប្រជាពលរដ្ឋដែលធ្វើការ តវ៉ាដោយអហឹង្សា។ ទោះជាយ៉ាងណាក៏ដោយនៅថ្ងៃនោះការិយាល័យនោះបានបញ្ជូនសំណើនោះរួចហើយ ហើយកំពុងរង់ចាំការសម្រេចរបស់គណៈកម្មាការអភិរក្សក្តើដំណែល ដែលបានលើកឡើងនូវសំនួរមួយ ចំនួន។

ប្រភព : Hindustan Times, New Delhi, ថ្ងៃសុក្រ ទី១៧ ខែតុលា ឆ្នាំ២០០៨

-------------------------------------------------------------------------------------------------------------------------

### ៤. **ការដាក់បញ្ចូលតម្លាភាពទៅក្នុងប្រព័ន្ធត្រួតពិនិត្យ - Chhattisgarh**

ភាពមិនប្រក្រតីនៅក្នុងការត្រួតពិនិត្យ និងការវាយតម្លៃរបស់គណៈកម្មការសេវាសាធារណៈ Chhatt- isgarh ត្រូវបានលាតត្រដាង បន្ទាប់ពីមានក្រុមអ្នកចង់ដឹងបានដាក់សំណើរសុំត្រួតពិនិត្យស្របតាម

ច្បាប់ RTI នៅក្នុងឆ្នាំ ២០០៦ ។

ជាលទ្ធផល គេបានធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងបែបបទត្រួតពិនិត្យ ហើយគណៈកម្មការនោះបានទទួលសារ ភាពពីកំហុសរបស់ខ្លួនចំពោះមុខតុលាការជាន់ខ្ពស់ ។ Ravindra Singh ជាប្រធានរបស់ Pratiyogi Sangarsh Manch (វេទិកាអ្នកតស៊ូដើម្បីយុត្តិធម៌) មានប្រសាសន៍ថា គណៈកម្មការនោះបានទទួល ស្គាល់កំហុសដែលធ្វើឡើងក្នុងគោលបំណងចែកផលចំណេញ ។ នៅពេលនោះ នីតិវិធីជ្រើសរើសទាំងមូលមានភាពផ្ទុយគ្នា ។

Singh បាននិយាយថា "នៅក្នុងឆ្នាំ២០០៦ តុលាការបានចេញសេចក្តីជូនដំណឹងទៅដល់បេក្ខជនទាំង ១៤៧នាក់ ដែលត្រូវបានជ្រើសរើសដោយគណៈកម្មការ" ។ ប្រធានគណៈកម្មការចាស់ឈ្មោះ Ashok Darbari ត្រូវបានគេផ្អាកពីការងារ ហើយលេខាឈ្មោះ Manohar Pandey និងអ្នកគ្រប់គ្រងការត្រួតពិនិត្យឈ្មោះ D.P. Kashyap ត្រូវបានបញ្ឈប់ពីការងារ ហើយមានសមាជិកម្នាក់ទៀតមានបំណងចង់លាឈប់ ។

"គណៈកម្មការនោះបានប្រាប់តុលាការថា ពួកគេនឹងរៀបចំធ្វើការត្រួតពិនិត្យមួយផ្សេងទៀតទៅលើអ្នកទាំងនោះ ក្រោយពីបានលុបចោលនូវលទ្ធផលឆ្នាំ២០០៦ ។ ការបើកសាវនការចុងក្រោយ គឺស្ថិតក្នុងការរង់ចាំ" ។

ប្រភព : Hindustan Times, New Delhi, ថ្ងៃសុក្រ ទី១៧ ខែតុលា ឆ្នាំ២០០៨

---

**៥. ការទទួលប្រាក់ឧបត្ថម្ភសម្រាប់សាងសង់លំនៅដ្ឋាន – Gujarat**

KASHIRAM SENVE ដែលជាពលករម្នាក់គ្មានដីធ្លី មានការភ្ញាក់ផ្អើលនៅពេលដែលគាត់បានទទួលសេចក្តី ជូនដំណឹងពីនាយកដ្ឋានសុខមាលភាពសង្គមរបស់រដ្ឋ ។ គាត់ត្រូវបានគេស្នើឱ្យសងប្រាក់វិញចំនួន ១០ ០០០រូពី ដែលជាប្រាក់កម្ចីគាត់បានយកមកសាងសង់លំនៅដ្ឋាន ។

នៅក្នុងឆ្នាំ ១៩៩៧-៩៨ Kashiram ដែលជាមនុស្សក្នុងវណ្ណៈសូទ្ររស់នៅក្នុងភូមិ Keshavpura ក្នុងស្រុក Ahmedabad ត្រូវបានផ្តល់ប្រាក់ឱ្យចំនួន ៤០ ០០០រូពី ស្ថិតក្រោមក្របខ័ណ្ឌ Ambedkar Awas Yojana ដើម្បីសាងសង់ផ្ទះរបស់គាត់ ។ ប៉ុន្តែ ចំនួនទឹកប្រាក់នោះមិនបានធ្លាក់ដល់ដៃគាត់ទាល់តែសោះ ។ ៦ឆ្នាំក្រោយមក នៅខែឧសភា ឆ្នាំ២០០៤ គាត់បានទទួល សេចក្តីជូនដំណឹងមួយដោយសុំឱ្យគាត់សងប្រាក់វិញចំនួន ១០ ០០០រូពី ដោយសារតែគាត់មិនបានសង់ផ្ទះរបស់គាត់ទេ ។

Kashiram បានធ្វើដំណើរទៅជួបក្រុមប្រឹក្សាភូមិ ហើយគេបានបញ្ជាប់ប្រាប់គាថា កំណត់ត្រារបស់គាត់ នោះមិនបានបង្ហាញពីបំណុលដែលគាត់ត្រូវសងនោះទេ។ ប៉ុន្តែនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៧ គាត់បានទទួលសេចក្តី ជូនដំណឹងមួយផ្សេងទៀតដោយស្នើឱ្យគាត់សងប្រាក់បន្ថែមទៀតចំនួន ៦ ៣៥០រូពី។ នៅពេលនោះ គាត់បាន ងាកទៅប្រើច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានវិញម្តង។ ប៉ុន្តែ ដំណើរការនោះមិនបានប្រព្រឹត្តិទៅដោយរលូននោះ ទេ ដោយហេតុថា មន្ត្រីមន្ទីរសុខមាលភាពសង្គមស្រុក បានគំរាមកំហែង និងបានប្រាប់គាត់ឱ្យដកពាក្យស្នើសុំ នោះចេញវិញ ដោយធ្វើការឆ្លើយបតចំពោះគាត់តែបន្តិចបន្តួចប៉ុណ្ណោះ។

អាជ្ញាធរបានចាត់វិធានការចំពោះរឿងក្តីរបស់គាត់ ក្រោយពីគាត់បានដាក់បណ្តឹងឧទ្ធរណ៍លើកទី២។ គាត់ត្រូវ បានគេផ្តល់ប្រាក់ឱ្យចំនួន ៤០ ០០០រូពី ដោយក្នុងនោះគាត់ត្រូវបានគេបើកប្រាក់ក្នុងដំណាក់កាលទីមួយចំនួន ២០ ០០០រូពីសិន។

ប្រភព : Hindustan Times, New Delhi, ថ្ងៃសុក្រ ទី១៧ ខែតុលា ឆ្នាំ២០០៨

---

[i] ឧបសម្ព័ន្ធស្តីពីទស្សនៈយល់ឃើញចំពោះអំពើពុករលួយនៅឆ្នាំ២០០៦ គឺជាឧបសម្ព័ន្ធបន្ថែមដោយសំអាងទៅលើការស្ទង់មតិអ្នកជំនាញផ្សេងៗគ្នា ដែលស្សនៈយល់ឃើញជារួមចំពោះអំពើពុករលួយនៅក្នុងវិស័យសាធារណៈនៅក្នុងប្រទេសចំនួន១៦៣ នៅជុំវិញពិភពលោក គឺជាទំហំដ៏ធំបំផុតដែល CPI បានកត់ត្រា។ គេឱ្យពិន្ទុប្រទេសទាំងនោះកម្រិតពី 0 - ១0 ហើយលេខសូន្យបង្ហាញពីកម្រិតខ្ពស់នៃអំពើពុករលួយ ហើយលេខ ១0 បង្ហាញពីកម្រិតទាបនៃអំពើពុករលួយដែលកើតមាន។

ប្រភព : ដកស្រង់ចេញពី PRIA (២០០៨), *ការទាមទារគណនេយ្យភាពពីរដ្ឋ : ការវាយតម្លៃសិទ្ធិទទួលព័ត៌មាន* New Delhi និង *ការទទួលបានព័ត៌មានស្របតាមច្បាប់ RTI: បទពិសោធន៍របស់ប្រជាពលរដ្ឋនៅក្នុងរដ្ឋចំនួន ១០,* New Delhi